# សំណួរដែលចោទសួរញឹកញាប់ អំពីអ្នកខ្ចីប្រាក់ Mass HAF

បានធ្វើបច្ចុប្បន្នភាពចុងក្រោយ៖ ថ្ងៃទី *1* ខែមេសា ឆ្នាំ *2023*

## 1. តើខ្ញុំមានសិទ្ធិទទួលជំនួយ តាមរយៈ Mass HAF ឬទេ?

អ្នកអាចនឹងមានសិទ្ធិទទួល ថវិកាជំនួយម្ចាស់ផ្ទះ រដ្ឋម៉ាស្សាជូសេត្ត (Massachusetts Homeowners Assistance Fund, Mass HAF) បើសិនអ្នកសមស្របតាមការតម្រូវទាំងអស់ នៅខាងក្រោម៖

- អ្នកមានផ្ទះខ្លួនឯង និងរស់នៅក្នុងផ្ទះគ្រួសារទោល, ផ្ទះកុនដូ, ឬផ្ទះគ្រួសារ 2- 3- ឬ 4 នាក់ បិតក្នុងរដ្ឋម៉ាស្សាជូសេត្ត។ ផ្ទះនេះត្រូវតែជាលំនៅដ្ឋាន ជាបឋមរបស់អ្នក។
- ពីព្រោះតែជំងឺ COVID-19 រាតត្បាត ប្រាក់ចំណូលរបស់អ្នកបានធ្លាក់ចុះ ឬការចំណាយលើការរស់នៅ បានកើនឡើង នៅចំថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 21 ខែមករា 2020។ ឧទាហរណ៍ អ្នកអាចនឹងធ្លាប់បានបាត់បង់ការងាររបស់អ្នក មានម៉ោងធ្វើការតិចជាងមុន ត្រូវចំណាយប្រាក់ច្រើនជាងមុនសម្រាប់ការថែទាំកូន មានជំងឺ ឬមិនអាចធ្វើការបាន ដោយសារតែអ្នកចាំបាច់ត្រូវមើលថែទាំសមាជិកគ្រួសារ។
- អ្នកបានខានបង់ប្រាក់បុលផ្ទះ យ៉ាងហោច 3 ដង ឬច្រើនជាង ចាប់តាំងពីថ្ងៃទី 21 ខែមករា 2020 មក។ ការបង់ប្រាក់មិនចាច់ជាប់ៗគ្នាទេ។ តែយ៉ាងណាមិញ បានខានបង់ប្រាក់ ត្រូវតែមានជំពាក់យ៉ាងហោច 3 ដង ឬច្រើនជាង នៅពេលដាក់ពាក្យសុំ។
- កម្ចីគេហដ្ឋានមិនមានការពន្យារពេលទូទាត់នោះទេនៅពេលនេះ។
- នៅពេលបង្កើតឡើងដំបូង កម្ចីគេហដ្ឋានរបស់អ្នកមានសមតុល្យប្រាក់ដើមដែល**មិន** លើសពីដែនកំណត់កម្ចីអនុលោមតាមលក្ខន្តិកៈ ARPA ។ សូមពិនិត្យមើលសំណួរទី 5 សម្រាប់ព័ត៌មានបន្ថែម។
- បើសិនអ្នកឃឹតបង់ប្រាក់បុលផ្ទះរបស់អ្នក យ៉ាងហោចចំនួនបីខែ អ្នកអាចនឹងមានសិទ្ធិទទួលជំនួយ ដោយមានការទារថ្លៃទ្រព្យខ្លះ ដូចជាជំពាក់ការបង់ពន្ធទ្រព្យ, ការធានារ៉ាប់រង, ឈ្នួលផ្ទះកុនដូ, តម្លៃរបស់ក្រុង ដូចជា ថ្លៃទឹក និងលូទឹកស្អុយ។ កម្មវិធី**មិន**ធានា ថាតម្លៃទាំងនេះ នឹងបានរ៉ាប់រងទេ ហើយបំណុលខានបង់ ត្រូវតែទាក់ទងនឹងការពារ នូវការរឹបអូសយកផ្ទះរបស់អ្នក។
- អ្នកស្របតាមការតម្រូវប្រាក់ចំណូលជាក់លាក់។ ដើម្បីឆែកមើល ថាតើអ្នកស្របតាមការតម្រូវប្រាក់ចំណូល នៅតំបន់របស់អ្នក ចុចកន្លែងនេះ។

## 2. តើមានអ្វីកើតឡើងបើខ្ញុំមិនទាន់យឺតយ៉ាវក្នុងការបង់ប្រាក់ចំនួនបីដងនៅឡើយ? តើខ្ញុំនៅតែអាចដាក់ពាក្យសុំបានដែរឬទេ?

ដើម្បីមានសិទ្ធិទទួលបាន អ្នកត្រូវតែយឺតយ៉ាវក្នុងការបង់ប្រាក់យ៉ាងតិចចំនួន 3 ដង នៅលើកម្ចីគេហដ្ឋានរបស់អ្នក។

ប្រសិនបើអ្នកមិនឃើញតយ៉ាវនៅលើកម្ចីគេហដ្ឋានរបស់អ្នក ដោយសារតែអ្នកមានកម្ចីគេហដ្ឋានសម្រាប់មនុស្សវ័យចំណាស់របស់អ្នក សូមមើលសំណួរទី 18។

3. **តើមូលនិធិជំនួយ Mass HAF មានផ្តល់ជូនរយៈពេលប៉ុន្មាន?**

អ្នកអាចដាក់ពាក្យសុំមូលនិធិជំនួយ Mass HAF រហូតដល់ថ្ងៃទី **30 ខែមិថុនា ឆ្នាំ 2023**។ ចាប់ផ្តើមនៅថ្ងៃទី **1 ខែកក្កដា ឆ្នាំ 2023** កម្មវិធីជំនួយលំនៅដ្ឋានដែលរដ្ឋផ្តល់មូលនិធិសម្រាប់គ្រួសារនៅក្នុងអន្តរកាល (Residential Assistance for Families in Transition, RAFT) នឹងមានផ្តល់ជូនដល់ម្ចាស់លំនៅដ្ឋានដែលមានប្រាក់ចំណូលទាបដែលមានហានិភ័យប្រឈមនឹងការរឹបអូសផ្ទះ។ នៅពេលនោះ ម្ចាស់លំនៅដ្ឋានដែលមានសិទ្ធិទទួលបានអាចនឹងដាក់ពាក្យសុំ RAFT តាមរយៈប្រព័ន្ធផតថលជំនួយទូទាត់ផ្នែកលំនៅដ្ឋានក្នុងគ្រាមានអាសន្ននៃក្រសួងលំនៅដ្ឋាននិងការអភិវឌ្ឍសហគមន៍។

4. **តើចំណាយប្រភេទអ្វី អាចនឹងបានរ៉ាប់រងដោយ Mass HAF?**

អ្នកដាក់ពាក្យស្នើសុំត្រូវតែខកខានការទូទាត់ប្រាក់កម្ចីទិញផ្ទះយ៉ាងហោចណាស់ 3 [ខែ] ឬច្រើនជាងនេះចាប់តាំងពីថ្ងៃទី 21 ខែមករា ឆ្នាំ 2020 ដើម្បីទទួលបានសិទ្ធិសម្រាប់កម្មវិធី Mass HAF។ ការខកខានទូទាត់ទាំងនេះត្រូវតែមិនទាន់សងនៅពេលដាក់ពាក្យស្នើសុំ។ អ្នកនឹងត្រូវបានស្នើឱ្យដាក់របាយការណ៍បញ្ជាំរបស់អ្នកជាផ្នែកនៃពាក្យស្នើសុំរបស់អ្នក។ ប្រសិនបើត្រូវបានអនុម័ត គ្រួសារមានសិទ្ធិទទួលបានជំនួយរហូតដល់ 50,000 ដុល្លារ។

ការចំណាយផ្សេងទៀត ដូចជា៖ ការធានារ៉ាប់រង ថ្លៃខុនដូ និងការបង់ថ្លៃសេវាកម្មឱ្យរដ្ឋបាលក្រុងអាចមានសិទ្ធិក្នុងស្ថានភាពហិរញ្ញវត្ថុមានកំណត់ នៅពេលដែលមានឯកសិទ្ធិលើទ្រព្យសម្បត្តិ ឬអាចមានឯកសិទ្ធិដោយសារការមិនទាន់បង់ថ្លៃទូទាត់ផ្សេងទៀត។ ជំនួយក្នុងការជួយដល់ការទូទាត់ថ្លៃទាំងអស់នេះត្រូវតែទាក់ទងនឹងការការពារពីការរឹបអូសផ្ទះរបស់អ្នក ឬការពារពីសិទ្ធិឃាត់ទុក។

5. **តើកម្ចីទិញផ្ទះប្រភេទណាខ្លះ ដែលមានសិទ្ធិទទួលបានជំនួយតាមរយៈ Mass HAF?**

ប្រាក់កម្ចីទិញផ្ទះរបស់ម្ចាស់ផ្ទះមិនអាចលើសពីអ្វីដែលគេហៅថា "ការអនុលោមតាមដែនកំណត់ប្រាក់កម្ចី។" ប្រាក់កម្ចីទិញផ្ទះដែលម្ចាស់ផ្ទះកំពុងដាក់ពាក្យមិនអាចលើសពីដែនកំណត់ដែលបានរាយនៅទីនេះនៅពេលពួកគេយកប្រាក់កម្ចីនោះទេ (ចំនួនដើមនៃប្រាក់កម្ចីទិញផ្ទះ)៖ សូមចុចទីនេះសម្រាប់បញ្ជីនៃការអនុលោមតាមដែនកំណត់ប្រាក់កម្ចីតាមឆ្នាំកម្ចីដំបូង។

ប្រាក់កម្ចីដែលបច្ចុប្បន្នស្ថិតក្នុងការលើកលែង ឬមិនទាន់ដល់ការកំណត់សង គឺមិនមានសិទ្ធិស្នើសុំនោះទេ រហូតដល់ការលើកលែងនោះបានបញ្ចប់។

6. **តើឯកសារបែបអ្វី បានត្រូវការមកជាមួយ ពាក្យសុំរបស់ខ្ញុំ?**

ប្រភេទនៃឯកសារខាងក្រោម អាចនឹងបានសូម នៅក្នុងពាក្យសុំ អាស្រ័យទៅលើជំនួយដែលអ្នកស្នើះ

- ឯកសារប្រាក់ចំណូល
- របាយការណ៍ប្រាក់បុលផ្ទះ ឬឯកសារប្រាក់បុលផ្ទះ ផ្សេងទៀត
- របាយការណ៍ពន្ធទ្រព្យ មកពីក្រុង ឬទីក្រុងរបស់អ្នក
- វិក្កយបត្រទូទាត់សេវាសាធារណៈទីក្រុង (ឧទាហរណ៍ វិក្កយបត្រទឹក និងលូ)
- អត្តសញ្ញាណប័ណ្ណ ដូចជា ID រដ្ឋ, អាជ្ញាប័ណ្ណអ្នកបើកបរ, ឬ លិខិតឆ្លងដែន

ឯកសារបន្ថែម អាចនឹងបានស្នើសុំ ប្រយោជន៍ដើម្បីបញ្ជាក់សិទ្ធិទទួលរបស់អ្នក។

7. **តើពាក្យសុំរបស់ខ្ញុំ អាចចាត់ទុកជាចំបង សំរាប់ការគិតគូរឆាប់រហ័សជាង ឬទេ?**

បច្ចុប្បន្ន ការផ្តល់អាទិភាពតែមួយគត់គឺសម្រាប់ម្ចាស់លំនៅដ្ឋានដែលប្រឈមនឹងការរឹបអូសផ្ទះមិនទាន់ដាច់ស្រេច (ឧ.ទា. កាលបរិច្ឆេទដេញថ្លៃ)។ យើងរំពឹងមានកាលៈទេសៈពិសេសខ្លះ នឹងកើតឡើងតាមរយៈការចាត់ចែងករណីដែលនឹងបានចាត់ទុកជាចំបង តាមត្រូវការ។

8. **តើអ្វីមានសិទ្ធិទទួល ជាឥទ្ធិពលនៃ COVID?**

អ្នកត្រូវតែធ្លាប់ឆ្លងកាត់ភាពលំបាកផ្នែកហិរញ្ញវត្ថុ ដូចជាការថយចុះប្រាក់ចំណូល ឬការកើនឡើងការចំណាយក្នុងការរស់នៅ ដែលកើតឡើងដោយសារការរាតត្បាតនៃវីរុសកូរ៉ូណា។ ការនេះអាចរួមមាន ប៉ុន្តែមិនកម្រិតចំពោះ បាត់បង់ការងារ, ការបន្ថយម៉ោងធ្វើការ, កើនតម្លៃ ដោយព្រោះការថែទាំកូន, ការឈឺថ្កាត់, ឬត្រូវការដើម្បីថែទាំ សមាជិកគ្រួសារ ចាប់តាំងពីថ្ងៃទី 21 ខែមករា 2020។ ការនេះអាចរួមមានលំបាកដែលបានចាប់ផ្តើម នៅមុនថ្ងៃទី 21 ខែមករា 2020 និងបានបន្តបន្ទាប់ពីថ្ងៃនោះ ប៉ុន្តែតម្លៃបានកើនឡើងបន្ទាប់ពីថ្ងៃទី 21 ខែមករា 2020 គឺមានសិទ្ធិទទួលជំនួយ HAF។

9. **ចុះបើខ្ញុំជំពាក់ច្រើនជាង 50,000 ដុល្លារ?**

**Mass HAF នឹងបង់ប្រាក់រហូតដល់ 50,000 ដុល្លារ** ហើយអ្នកផ្តល់សេវារបស់អ្នក (អ្នកផ្តល់សេវារបស់អ្នកគឺជាអ្នកណាដែលអ្នកបង់ប្រាក់បញ្ចាំរបស់អ្នក) អាចមានលទ្ធភាពផ្តល់ជំនួយជាមួយនឹងផែនការដើម្បីជួយអ្នកឱ្យដឹងពីចំនួននៅសល់ដែលអ្នកជំពាក់។ ផែនការមួយអាស្រ័យលើអ្វីដែលអ្នកផ្តល់សេវារបស់អ្នកកំពុងផ្តល់ជូន ប៉ុន្តែអាចរួមបញ្ចូលការដាក់ប្រាក់មួយចំនួនដែលអ្នកជំពាក់នៅចុងបញ្ចប់នៃប្រាក់កម្ចីទិញផ្ទះរបស់អ្នក ហើយការពន្យារពេលសម្រាប់ឆ្នាំបន្ថែមមួយចំនួន។ សម្រាប់ម្ចាស់ផ្ទះភាគច្រើន អ្នកផ្តល់សេវារបស់អ្នកនឹងទាក់ទងទៅអ្នក ហើយស្វែងរកផែនការសម្រាប់សមតុល្យដែលនៅសល់។

**<u>ចំណាំះ វាមិនត្រូវបានធានានោះទេ អ្នកផ្តល់សេវានឹងជួយចំពោះសមតុល្យជំពាក់ដែលនៅសល់របស់អ្នក។</u>**

**10. តើខ្ញុំត្រូវសងជំនួយអ្វីមួយដែលខ្ញុំទទួល ឬទេ?**

ទេ ជំនួយអ្វីមួយដែលបានទទួលតាមរយៈ Mass HAF គឺមិនមែនជាប្រាក់កម្ចីទេ ហើយនឹងមិនត្រូវបានសងទេ។

**11. តើអត្ថប្រយោជន៍ដែលខ្ញុំទទួល ត្រូវបានចាត់ទុកជាប្រាក់ចំណូលបង់ពន្ធ ឬទេ?**

ទេ ជំនួយអ្វីមួយដែលបានទទួលតាមរយៈ កម្មវិធី Mass HAF សំរាប់ជំនួយមានសិទ្ធិទទួល ការចំណាយទាក់ទងនឹងផ្ទះ គឺមិនចាត់ទុកជាប្រាក់ចំណូលបង់ពន្ធទេ។ អ្នកដាក់ពាក្យសុំដែលមានសិទ្ធិទទួល នឹងមិនបានតម្រូវឲ្យបង់ពន្ធលើជំនួយដែលមានសិទ្ធិទទួល បានទទួលតាមរយៈ Mass HAF ឡើយ។

**12. តើ Mass HAF ជួយជាមួយការបង់ប្រាក់ផ្ទះចល័ត ឬទេ?**

Mass HAF អាចជួយជាមួយការបង់ប្រាក់កម្ចីផ្ទះចល័ត សំរាប់បំណុលខានបង់ ទាក់ទងទៅនឹងការជួលដី និងការបង់ ប្រាក់កម្ចីថ្លៃដី។

**13. តើខ្ញុំអាចដាក់ពាក្យសុំ សំរាប់ទ្រព្យទាំងអស់របស់ខ្ញុំ ឬទេ?**

ទេ ថវិកា Mass HAF អាចបានចែកចាយទៅឲ្យតែអ្នកដាក់ពាក្យសុំ សំរាប់លំនៅដ្ឋានជាបឋមរបស់គេ ឋិតនៅក្នុងរដ្ឋម៉ាស្សាជូសេត្ត។

**14. តើខ្ញុំអាចទទួលជំនួយ ក្នុងការបញ្ជូនពាក្យសុំរបស់ខ្ញុំ ដូចម្តេច?**

មូលនិធិជំនួយ Mass HAF បានចុះកិច្ចសន្យាជាមួយនឹងទីភ្នាក់ងារពិគ្រោះយោបល់លំនៅដ្ឋាន (HCA) នៅទូទាំងរដ្ឋដើម្បីជួយម្ចាស់លំនៅដ្ឋាន។ HCA អាចជួយជាមួយការបំពេញពាក្យសុំ រួមទាំងការផ្ទេរបញ្ចូលឯកសារ តាងនាម របស់អ្នកផង។ អ្នកអាចរកឃើញ HCA នៅក្នុងតំបន់របស់អ្នក និងព័ត៌មានទំនាក់ទំនង ដោយទស្សនា ឧបករណ៍រក HCA និងដោយបញ្ចូល ស៊ីបកូដរបស់អ្នក។

លើសពីនេះទៀត Mass HAF Call Center អាចផ្តល់សភាពការណ៍ ស្តីពីស្ថានភាពការដាក់ពាក្យសុំ និងជំនួយបច្ចេកទេស ការដាក់ពាក្យសុំ។ អ្នកអាចទាក់ទងទៅកាន់មជ្ឈមណ្ឌលទំនាក់ទំនងមូលនិធិជំនួយ Mass HAF តាមទូរស័ព្ទលេខ 833-270-2953 ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ម៉ោង 10:00 ព្រឹក - 8:00 យប់។ សេវាអ្នកបកប្រែ គឺមានជាច្រើនភាសា។ សំរាប់បញ្ជីនៃភាសា សូមមើលសំណួរទី 19។ អ្នកដាក់ពាក្យសុំដែលថ្លង់ ត្រចៀកធ្ងន់ ទើបបានថ្លង់ ឬពិការសំដី អាចចុចលេខ 711 ដើម្បីតភ្ជាប់។ សំរាប់ព័ត៌មានថែមទៀត សូមមើលសំណួរទី 31។

**15. តើប្រាក់ចំណូលក្រុមគ្រួសារ ចំនួនប៉ុន្មានត្រូវបានគិតគូរ?**

ប្រាក់ចំណូលត្រូវបានគិតគូរ សំរាប់សមាជិកក្រុមគ្រួសារ ដែលចុះរាយនៅលើឯកសារប្រាក់បុលផ្ទះ និងកំពុងរស់នៅក្នុងផ្ទះ។ ប្រាក់ចំណូលផ្សេងទៀត របស់សមាជិកក្រុមគ្រួសារ គឺមិនបានបញ្ចូលសំរាប់គោលបំណង ការដាក់ពាក្យ

សុំទេ។ អ្នកអាចប្រើ ប្រដាប់គិតលេខ ប្រាក់ចំណូលមានសិទ្ធិទទួល HAF ដើម្បីសំរេច បើសិនអ្នកស្របតាមការតម្រូវប្រាក់ចំណូលមានសិទ្ធិទទួល។

**16. តើ Mass HA អាចជួយជាមួយបំណុលខានបង់ ពីមុនថ្ងៃទី 21 ខែមករា 2020 ឬទេ?**

ទេ មូលនិធិជំនួយ Mass HAF នឹងរ៉ាប់រងតែប្រាក់ជំពាក់មិនទាន់បង់ដល់ម្ចាស់លំនៅដ្ឋានដែលមានសិទ្ធិទទួលបាននៅក្រោយថ្ងៃទី 21 ខែមករា ឆ្នាំ 2020 តែប៉ុណ្ណោះ។ តែយ៉ាងណាមិញ បើសិនអ្នកមានបំណុលខានបង់ប្រាក់បុលផ្ទះ ទាំងនៅមុនថ្ងៃ និងបន្ទាប់ពី ថ្ងៃទី 21 ខែមករា 2020 ហើយស្របតាមលក្ខណៈសិទ្ធិទទួល នោះចំណែកនៃបំណុលខានបង់ប្រាក់បុលផ្ទះរបស់ អ្នក បន្ទាប់ពីថ្ងៃទី 21 ខែមករា 2020 អាចនឹងមានសិទ្ធិទទួលជំនួយ។

បើសិនអ្នកត្រូវការជំនួយ ជាមួយបំណុលខានបង់ មុនថ្ងៃទី 21 ខែមករា 2020 ភ្នាក់ងារប្រឹក្សាលំនៅ (HCA) ប្រហែលអាចជួយអ្នក ដើម្បីរកធនធាន និងការណែនាំបន្ថែម។ Mass HAF មានកិច្ចសន្យាជាមួយ HCA នៅពាសពេញរដ្ឋ ដើម្បីជួយអ្នកដាក់ពាក្យសុំ។ សំរាប់ព័ត៌មានថែមទៀត អំពីរបៀបទាក់ទង ជាមួយ HCA ក្នុងតំបន់ សូមមើលសំណួរទី 14។

**17. តើ Mass HAF នឹងជួយខ្ញុំឬទេ បើសិនខ្ញុំយឺតបង់ពន្ធទ្រព្យ ឬឈ្នួលផ្ទះកុនដូ ប៉ុន្តែពុំមានប្រាក់បុលផ្ទះ ឬខ្ញុំមិនយឺតបង់ប្រាក់បុលផ្ទះរបស់ខ្ញុំ?**

ទេ កម្មវិធីមិនផ្តល់ជូនជំនួយនេះដល់ម្ចាស់លំនៅដ្ឋានដែលគ្មានកម្ចីលំនៅដ្ឋាននៅពេលនេះទេ។

**18. តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមានកម្ចីលំនៅដ្ឋានសម្រាប់មនុស្សវ័យចំណាស់ ប៉ុន្តែខ្ញុំហួសពេលក្នុងការគិតប្រាក់ថ្លៃអចលនទ្រព្យផ្សេងទៀតទេ? តើខ្ញុំអាចមានសិទ្ធិទទួលបានជំនួយដែរឬទេ?**

បាទ ម្ចាស់លំនៅដ្ឋានដែលមានកម្ចីសម្រាប់មនុស្សវ័យចំណាស់ គឺមានសិទ្ធិទទួលបានជំនួយ។ ដើម្បីមានសិទ្ធិទទួលបាន ម្ចាស់លំនៅដ្ឋានត្រូវតែមានការគិតប្រាក់ពន្ធអចលនទ្រព្យក្រុងដែលម្ចាស់លំនៅដ្ឋានបានខកខានមិនបានបង់ប្រាក់ពន្ធអចលនទ្រព្យប្រចាំត្រីមាសចំនួនបីដង ឬបានទទួលលិខិតទាមទារពីក្រុង និង/ឬការគិតប្រាក់សេវាសាធារណៈក្រុងដែលហួសពេលកំណត់បង់ ដោយមានលិខិតបញ្ជាក់អំពីសិទ្ធិឃាត់ទុកបច្ចុប្បន្ន។

**19. តើពាក្យសុំមានជាភាសាផ្សេងទៀត ក្រៅពីអង់គ្លេស ឬទេ?**

បាទ/ចាស។ ពាក្យសុំ Mass HAF តាមអនឡាញ គឺមានជា 7 ភាសាផ្សេងទៀត ក្រៅពីអង់គ្លេស; ចិន, ហេទី-ក្រអូល, អេស្បាញ៉ុល, ព័រទុហ្គី, វៀតណាម, ខ្មែរ, និង រុស្ស៊ី។ លើសពីនេះទៀត ក៏មានសេវាអ្នកបកប្រែ ជាច្រើនភាសា សំរាប់ Mass HAF Call Center (833-270-2953)។

## 20. តើខ្ញុំនឹងត្រូវបានជំរាប ពីការទទួលរង្វាន់ HAF ឬទេ?

អ្នកនឹងត្រូវបានជំរាប ពីការឲ្យរង្វាន់ HAF ផ្តាច់ព្រ័ត្រ និងការបំបែក នូវថវិកាត្រូវបានធ្វើឲ្យដូចម្តេច តាមរយៈអ៊ីមែល ឬដោយឡុកចូលទៅ ច្រកគេហទំព័រ។ អ្នកនឹងមិនទទួលប្រាក់ ដោយផ្ទាល់ទេ។ រង្វាន់នឹងទៅម្ចាស់កម្ចីប្រាក់បុលផ្ទះ របស់អ្នកដោយផ្ទាល់ ដែលបន្ទាប់មក នឹងអនុវត្តវាទៅក្នុងគណនី កម្ចីប្រាក់បុលផ្ទះ តាងនាមរបស់អ្នក។

## 21. តើវានឹងប្រើពេលយូរប៉ុណ្ណា សំរាប់ខ្ញុំដើម្បីទទួលជំនួយ បន្ទាប់ពីខ្ញុំដាក់ពាក្យសុំ?

នៅពេលអ្នកបានបំពេញពាក្យសុំរបស់អ្នក និងបានអាប់ឡូដរាល់ឯកសារចាំបាច់ទាំងអស់ កាលវេលានោះជាធម្មតាគឺនៅចន្លោះ 30-60 ថ្ងៃ ប៉ុន្តែភាគច្រើនគឺអាស្រ័យលើភាពឆាប់រហ័សដែលភ្នាក់ងារសេវារបស់អ្នកអាចប្រគល់លិខិតបញ្ជាក់អំពីភាពយឺតយ៉ាវក្នុងការសងមកឱ្យយើង។ យើងនឹងទាក់ទងទៅម្ចាស់កម្ចីប្រាក់បុលផ្ទះរបស់អ្នក ក្នុងព្រឹត្តិការណ៍ដែលគេមិនចូលរួមនៅឡើយ ហើយយើងនឹងជំរាបអ្នក ពីការពន្យារពេល ក្នុងការគិតគូរ បានបណ្តាលដោយសារបញ្ហានេះ។

## 22. តើម្ចាស់កម្ចី ត្រូវតែជាអ្នកចូលរួមក្នុងកម្មវិធី Mass HAF ឬទេ សំរាប់ខ្ញុំដើម្បីទទួលជំនួយ?

បាទ/ចាស នៅពេលនេះ ម្ចាស់កម្ចីត្រូវតែជាអ្នកចូលរួមក្នុងកម្មវិធី Mass HAF ដើម្បីទទួលជំនួយ។ Mass HAF កំពុងតែធ្វើការយ៉ាងសកម្ម ដើម្បីឲ្យម្ចាស់កម្ចីបានចូលរួមយ៉ាងច្រើនបំផុត។ បើសិនម្ចាស់កម្ចីរបស់អ្នក នៅបច្ចុប្បន្ននេះ មិនមែនជាអ្នកចូលរួមទេ អ្នកនៅតែស្វាគមន៍ឲ្យដាក់ពាក្យសុំ ហើយ Mass HAF នឹងធ្វើការជាមួយម្ចាស់កម្ចីរបស់អ្នក ដើម្បីជំរុញទឹកចិត្តការចូលរួមរបស់គេ នៅក្នុងកម្មវិធី។

## 23. តើម្ចាស់លំនៅដ្ឋាននឹងទទួលបានការសម្រេចផ្តល់ឱ្យនេះដោយផ្ទាល់ដែរឬទេ ?

ទេ អ្នកនឹងមិនទទួលប្រាក់ ដោយផ្ទាល់ទេ។ រង្វាន់នឹងឲ្យទៅម្ចាស់កម្ចីប្រាក់បុលផ្ទះ របស់អ្នកដោយផ្ទាល់ ដែលបន្ទាប់មក នឹងអនុវត្តវាទៅក្នុងគណនីកម្ចីប្រាក់បុលផ្ទះរបស់អ្នក។ ឈ្នួលនៃទីក្រុង, ក្រុមហ៊ុនធានារ៉ាប់រង និងសមាគមម្ចាស់ផ្ទះ នឹងបានបង់ប្រាក់ឲ្យដោយផ្ទាល់ សំរាប់ឈ្នួលអ្វីមួយនៃក្រុង ដែលមានសិទ្ធិទទួល, ថ្លៃពន្ធ, ការធានារ៉ាប់រង, និង/ឬ ឈ្នួលអាគារ ត្រូវបានចេញសងដោយកម្មវិធីនេះ។

## 24. តើខ្ញុំអាចទទួលជំនួយ សំរាប់ការបង់ប្រាក់នៅអនាគត ឬទេ?

នៅពេលនេះ កម្មវិធី Mass HAF មិនផ្តល់ជំនួយ សំរាប់ការបង់ប្រាក់បុលផ្ទះ នៅអនាគតទេ។ កម្មវិធីគឺបានប៉ងធ្វើឲ្យការជំពាក់ប្រាក់បុលផ្ទះបច្ចុប្បន្ន មានតុល្យភាព។

## 25. បើសិនខ្ញុំត្រូវការជំនួយបន្ថែម តើខ្ញុំអាចដាក់ពាក្យសុំម្តងទៀត ឬទេ?

នៅពេលនេះ ម្ចាស់លំនៅដ្ឋានមិនអាចដាក់ពាក្យសុំជំនួយសាឡើងវិញទេ។

**26. កម្ចីគេហដ្ឋានកំពុងមានការពន្យារពេលការទូទាត់នៅពេលនេះ។ តើខ្ញុំអាចដាក់ពាក្យសុំនៅថ្ងៃនេះបានដែរឬទេ ?**

មិនមែននៅពេលនេះទេ អ្នកមិនមានសិទ្ធិទទួលបានទេ ប្រសិនបើអ្នកកំពុងស្ថិតក្រោមការបន្ធូរបន្ថយសំណងកម្ចីលំនៅដ្ឋាននាពេលបច្ចុប្បន្ន លើកលែងតែអ្នកមានកម្ចីលំនៅដ្ឋានដែលបម្រើសេវាដោយទីភ្នាក់ងារ MassHousing (ទីភ្នាក់ងារហិរញ្ញវត្ថុលំនៅដ្ឋានរដ្ឋម៉ាសាជូសេត)។ មូលនិធិជំនួយ Mass HAF អាចនឹងរ៉ាប់រងលើការបង់ប្រាក់ដែលបានពន្យារពាក់ព័ន្ធនឹងជំងឺ COVID ដែលត្រូវបានបូកបន្ថែមដើម្បីបញ្ចប់កម្ចីលំនៅដ្ឋាន សម្រាប់ជាផ្នែកមួយនៃគម្រោងបន្ធូរបន្ថយសំណងកម្ចីលំនៅដ្ឋាន។ នេះអនុវត្តទៅលើអ្នកខ្ចីប្រាក់ MassHousing តែប៉ុណ្ណោះ។

**27. តើ Mass HAF នឹងបង់បំណុលខានបង់ លើប្រាក់បុលផ្ទះរបស់ខ្ញុំលើកទីពីរ ឬទេ?**

បាទ/ចាស បើសិនអ្នកមានសិទ្ធិទទួល និងយឺតបង់ប្រាក់បុលផ្ទះទីពីរ ចំនួន 3 ខែ ឬច្រើនជាង អ្នកអាចនឹងមានសិទ្ធិទទួលជំនួយ តាមរយៈ Mass HAF។

**28. តើខ្ញុំអាចដាក់ពាក្យសុំ Mass HAF ឬទេ បើសិនខ្ញុំមាន ឬធ្លាប់មាន ប្រាក់ជឿស៊ើតម្លៃផ្ទះ (Home Equity Line of Credit, HELOC) ពីមុន?**

បាទ/ចាស អ្នកអាចដាក់ពាក្យសុំ បើសិនអ្នកមានបំណុលខានបង់ យ៉ាងហោចបីដង លើ HELOC របស់អ្នកក្នុងរយៈពេលសិទ្ធិទទួល HAF តែយ៉ាងណាមិញ អ្នកត្រូវតែបិទ HELOC មុនពេលដាក់ពាក្យសុំ ឬអំឡុងពេលវិធីការដាក់ពាក្យសុំ។

**29. តើខ្ញុំអាចដាក់ពាក្យសុំ Mass HAF ឬទេ បើសិនខ្ញុំបានប្រកាសធនក្ស័យ ក្នុងជំពូក 13?**

បាទ/ចាស បើសិនអ្នកស្របតាមការតម្រូវសិទ្ធិទទួល Mass HAF ផ្សេងទៀត នោះបំណុលខានបង់ ទាក់ទងនឹងប្រាក់បុលទិញផ្ទះរបស់អ្នក គឺមានសិទ្ធិទទួល ឲ្យបានបង់ចេញពី HAF។

**30. បើសិនខ្ញុំត្រូវបានបដិសេធ តើមានវិធីឧទ្ធរណ៍ ឬទេ?**

បាទ/ចាស បើសិនអ្នកត្រូវបានបដិសេធ សំរាប់ជំនួយ តាមរយៈ Mass HAF អ្នកអាចធ្វើឧទ្ធរណ៍ ឬតវ៉ា ក្នុងពេល 14 ថ្ងៃ នៃការបដិសេធន៍។ អ្នកអាចធ្វើតាមវិធីឧទ្ធរណ៍ តាមរយៈច្រកគេហទំព័រ ដាក់ពាក្យសុំ Mass HAF ឬស្វែងរកជំនួយ ការបញ្ជូនឧទ្ធរណ៍ជាមួយ HCA។ អ្នកអាចរកមើល HCA នៅក្នុងតំបន់របស់អ្នក ដោយទស្សនា ឧបករណ៍រក HCA។ ការសំរេចលើឧទ្ធរណ៍ នឹងជាការឈ្វេងយល់ផ្ដាច់ព្រ័ត្រ នៃ Mass Housing Partnership។

**31. ខ្ញុំគឺជាមនុស្សថ្លង់ ត្រចៀកធ្ងន់ ទើបបានថ្លង់ ឬពិការសំដី។ តើខ្ញុំអាចទាក់ទងជាមួយ Mass HAF ដូចម្តេច?**

MassRelay ផ្តល់ជំនួយឥតគិតថ្លៃ និងជាសំងាត់។ ចុច 711 ដើម្បីតភ្ជាប់។ កាលណាបានតភ្ជាប់ ជាមួយអ្នកចាត់ការ បណ្តាក់សារ អ្នកគួរតែបានប្រាប់ពាក្យដោយ "NUMBERS PLS GA" ដែលមានន័យថា អ្នកចាត់ការគឺស្រេចបាច់ សំរាប់ឲ្យអ្នកដាក់បញ្ចូល លេខទូរស័ព្ទ ដែលអ្នកកំពុងព្យាយាមទាក់ទង។

លេខនៃមជ្ឈមណ្ឌលហៅ Mass HAF គឺ 833-270-2953។ ដើម្បីបញ្ជាក់ថាអ្នកកំពុងតែវាយអក្សរ ត្រូវសរសេរពាក្យ "GA" ដែលមានថា "ទៅមុខទៀត"។

**32. ខ្ញុំកំពុងមានអារម្មណ៍ធុញថប់ ហើយក៏ដូចជាអស់សង្ឃឹម – តើខ្ញុំអាចទូរស័ព្ទទៅនរណាដើម្បីឱ្យគេស្តាប់ពីបញ្ហារបស់ខ្ញុំ?**

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់កំពុងមានវិបត្តិសុខភាពផ្លូវចិត្ត និង/ឬ គំនិតចង់សម្លាប់ខ្លួន **សូមទូរស័ព្ទ ឬផ្ញើសារទៅលេខ 988** ដែលជាលេខទូរស័ព្ទជាតិផ្នែកអត្តឃាត និងវិបត្តិ។ ខ្សែទូរស័ព្ទសង្គ្រោះពេលធ្វើអត្តឃាត និងមានវិបត្តិ តាមរយៈលេខ 988 គឺអាចទាក់ទងបាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកក៏អាចទទួលបានមុខងារឆាតនៅលើគេហទំព័រ៖ https://988lifeline.org/contact-the-lifeline/

ប្រសិនបើអ្នកស្វែងរកអ្នកប្រកបដោយវិជ្ជាជីវៈដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការវាយតម្លៃសុខភាពផ្លូវចិត្ត និង/ឬការបញ្ជូនបន្តសម្រាប់សុខភាពផ្លូវចិត្ត សូមទាក់ទងទៅកាន់ខ្សែទូរស័ព្ទជំនួយសុខភាពអាកប្បកិរិយា រដ្ឋម៉ាសាជូសេត ដោយទូរស័ព្ទ ឬផ្ញើសារទៅកាន់លេខ 833-773-2445 (BHHL)។ ខ្សែទូរស័ព្ទជំនួយគឺអាចទាក់ទងបាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ អ្នកក៏អាចចូលទៅកាន់មុខងារឆាតនៅលើគេហទំព័រ៖ https://www.masshelpline.com/contact/#

**33. តើខ្ញុំអាចទទួលបានសៀវភៅណែនាំសម្រាប់ជំនួយលើការទូទាត់កម្ចីលំនៅដ្ឋានរបស់ខ្ញុំតាមរយៈណាដែរ ប្រសិនបើខ្ញុំគ្មានសិទ្ធិទទួលបានមូលនិធិជំនួយ Mass HAF?**

មានទីភ្នាក់ងារពិគ្រោះយោបល់លំនៅដ្ឋានចំនួន 40 នៅក្នុងរដ្ឋម៉ាសាជូសេតដែលអាចជួយអ្នកបាន។ ស្ថាប័នមិនរកប្រាក់កម្រៃទាំងនេះត្រូវបានឯកភាពដោយក្រសួងលំនៅដ្ឋាន និងការអភិវឌ្ឍជនបទសហរដ្ឋអាមេរិក (HUD) និងមានបុគ្គលិកមានបទពិសោធន៍នៅក្នុងការផ្តល់ការការពារការរឹបអូសលំនៅដ្ឋាន និងសេវានានា។ អ្នកផ្តល់សេវាទាំងនេះផ្តល់ការពិគ្រោះយោបល់អំពីការការពារការរឹបអូសលំនៅដ្ឋានដោយឥតគិតថ្លៃ។ អាចពិនិត្យមើលបញ្ជីរាយនាមទីភ្នាក់ងារពិគ្រោះយោបល់លំនៅដ្ឋាន នៅទីនេះ។

*ផែនការនេះ គឺកំពុងតែបានឧបត្ថម្ភ ជាទាំងស្រុង ឬផ្នែកខ្លះ ដោយរង្វាន់សហព័ន្ធលេខ HAF0174*
*បានឲ្យរង្វាន់ទៅ Commonwealth of Massachusetts ដោយក្រសួងរតនាគារសហរដ្ឋអាមេរិក។*